**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :..៥៧៦..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣ /០១៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឲ្យធ្វើនិយ័តកម្មឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងវ៉ែនិងថាមពល ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

**ក-និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែក)**

ឯកតា លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | **និយ័តកម្មចេញ** | | | | | |
| | **៩៩- ចំណាយមិនទាន់បែងចែក** | | | | 1 464 032 | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | 230 877 | 230 877 | - | 230 877 | 0 |
| ៦៥ | ឧបត្ថម្ភក្រុង ស្រុកនិងឃុំ សង្កាត់ | 375 326 | 375 326 | - | 305 056 | 70 270 |
| ៦៥ | ចំណាយចរន្តក្នុងការអនុវត្តគម្រោង | 150 000 | 150 000 | - | 20 000 | 130 000 |
| ០៩ | ចំណាយមិនបានគ្រោងទុក | 651 050 | 651 050 | - | 502 250 | 148 800 |
| ១៦ | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 330 924 | 330 924 | - | 330 924 | 0 |
| ២៧ | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 74 925 | 74 925 | - | 74 925 | 0 |
| | **និយ័តកម្មចូល** | | | 1 464 032 | | |
| | **១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | | 1 001 782 | | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | 0 | 0 | 230 877 | - | 230 877 |
| ៦៥ | ឧបត្ថម្ភក្រុង ស្រុកនិងឃុំ សង្កាត់ | 23 160 | 23 160 | 305 056 | - | 328 216 |
| ៦៣ | ពន្ធនិងអាករ | 131 400 | 131 400 | 60 000 | - | 191 400 |
| ១៦ | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 0 | 0 | 330 924 | - | 330 924 |
| ២៧ | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 0 | 0 | 74 925 | - | 74 925 |
| | **១៣- ក្រសួងរ៉ែនិងថាមពល** | | | 192 250 | | |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | 223 | 223 | 192 250 | - | 192 473 |
| | **២៥- ក្រសួងសាធារណការនិងដឹកជញ្ជូន** | | | 250 000 | | |
| ៦១ | សេវាខាងក្រៅ | 1 538 | 1 538 | 250 000 | - | 251 538 |
| | **២៨- ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ (ថវិកាកម្មវិធី )** | | | 20 000 | | |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | 43 268 | 43 268 | 20 000 | - | 63 268 |

ខ-និយ័តកម្មចេញពីទីស្តីការគណៈរដ្ឋមន្ត្រី

ឯកតា លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | និយ័តកម្មចេញ | | | | | |
| | ០៥.១-ទីស្តីការគណៈរដ្ឋមន្ត្រី | | | | 500 | . |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម (អាជ្ញាធរប្រេងកាតជាតិកម្ពុជា) | 161 645 | 161 645 | | 500 | 161 145 |
| | និយ័តកម្មចូល | | | | | |
| | ១៣-ក្រសួងរ៉ែនិងថាមពល | | | 500 | | |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | 223 | 192 473 | 500 | - | 192 973 |

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com